## សិទ្ធិរបស់ជនត្រូវចោទ (rights of defendant)

សិទ្ធិនេះ មានចែងនៅក្នុងមាត្រា១៤នៃកតិកាសញ្ញាស្ដីពីសិទ្ធិប្រជាពលរដ្ឋ (international covenant on civil and political rights) មានដូចជាសិទ្ធិសមភាពភាគី (equality of arms) សិទ្ធិសន្មតជាមុនថាមិនទាន់មានទោស (presumption of innocence) សិទ្ធិប្ដឹងឧទ្ធរណ៍ (right to appeal) សិទ្ធិការពារទល់ការកាត់សេចក្ដីពីរដង (double jeopardy) សិទ្ធិទទួលបានសំណងក្នុងករណី (right to compensation for wrongful conviction)។

សិទ្ធិទាំងនេះ ត្រូវបានសរសេរបញ្ចូលក្នុងលក្ខន្តិកៈ នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ដូចជាមាត្រា ៣៥នៃច្បាប់ស្ដីពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (Law on Extraordinary Chambers in the court of Cambodia: ECCC)។ សិទ្ធិទាំងនេះ ជាផ្នែកនៃសិទ្ធិទទួលបានការកាត់សេចក្ដីដោយយុត្តិធម៌ (fair trial)។ ឯកសារ មិនបានចែងច្បាស់ថា សិទ្ធិនេះជាសិទ្ធិដាច់ខាតមិនអាចផ្អាកអនុវត្តបានទេ (non-derogable rights)។ ទោះបីជាយ៉ាងនេះក្ដី មាននិន្នាការ ប្រកាន់ថា សិទ្ធិនេះមានលក្ខណៈដាច់ខាត។ អង្គការសហប្រជាជាតិ កំពុងសិក្សា និងកែសម្រួល ដាក់ឲ្យសិទ្ធិទាំងនេះ ជាសិទ្ធិដាច់ខាត។